ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតនៅឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

ដោយមានការគាំទ្រពី គណៈកម្មាធិការខុមហ្វ្រែល សហការជាមួយនឹង **សមាគមអាដហុក** បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយ ស្តីពី **ការកំណត់តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ដាច់ស្រយាល** ដែលធ្វើឡើងនៅ**ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ** កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ **៥១**នាក់ **(២៩%**ជាស្ត្រី មាន**៣%**ជាជនជាតិដើមភាគតិច**)** ពីគ្រប់ភូមិក្នុងឃុំ ដែលរួមមាន តំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ សមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង៥ នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្នយកចិត្តទុកដាក់ដោះស្រាយ និង/ឬ គណបក្សនយោបាយទទួលយកដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

### តម្រូវការជាអាទិភាពទាំង ៥ ក្នុងឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ

**១. ការស្នើសុំដីកសិកម្ម ដីសាងសង់លំនៅដ្ឋាន និងដីសង្គមកិច្ច**

- សុំ**ដីសង្គមកិច្ច**សម្រាប់ភូមិកោះផ្តៅចំនួន ៨៩៤ហិចតា មាន ១៦៩គ្រួសារ និងសុំ**ដីលំនៅដ្ឋាន**សម្រាប់១គ្រួសារ មានប្រវែង៤០ម៉ែត្រ ទទឹង២០ម៉ែត្រ។ សូមឲ្យបាននៅឆ្នាំ២០១២នេះ។
- សុំ**ដីកសិកម្ម**សម្រាប់**ភូមិទាំង៦** ដោយក្នុង១គ្រួសារៗចំនួន ៥ហិចតា ដែលភូមិទាំងនោះរួមមាន ៖ ភូមិទន្លេរាងធ្លាក់សម្រាប់១៧៨គ្រួសារ ភូមិអាជេនសម្រាប់១៦៥គ្រួសារ ភូមិកំពង់ក្របីសម្រាប់១៤៩គ្រួសារ ភូមិយាវសម្រាប់១៣៣គ្រួសារ ភូមិសំភិនសម្រាប់២៥៥គ្រួសារ តែដោយឡែកភូមិអំពិលទឹកសម្រាប់១៦០គ្រួសារ ដោយក្នុង១គ្រួសារៗចំនួនតែ២ហិចតាទេ។ សូមឲ្យបាននៅឆ្នាំ២០១២នេះ។

**២. ការធ្វើផ្លូវ និងស្ពាន**

- សុំធ្វើផ្លូវចំនួន**៦ខ្សែ** ជាប្រភេទផ្លូវលំក្រាលគ្រួសក្រហម និងមានទទឹង៧ម៉ែត្រដូចៗគ្នា តែប្រវែងខុសៗគ្នាគឺ៖

  - **ខ្សែទី១**នៅភូមិកំពង់ក្របី មានប្រវែង២០០០ម៉ែត្រ ពីចំណុចព្រំប្រទល់ភូមិកោះផ្តៅ ទៅទល់ព្រំប្រទល់

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

**ទីស្នាក់ការកណ្តាល** ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**Central Office** : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
**P.O. Box**1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

| |
|---|
| ភូមិអំពិលទឹក និងមាន**ដាក់លូ**៥កន្លែង ដោយ១កន្លែងៗមានលូ៧កង់ មានមុខកាត់៣តឹក ៤កន្លែង និងមុខកាត់៦តឹក១កន្លែង។<br>- **ខ្សែទី២**នៅភូមិអំពិលទឹកមានប្រវែង២៥០០ម៉ែត្រ ពីចំណុចព្រំប្រទល់កំពង់ក្របី ទៅព្រំប្រទល់ឃុំបឹងចារ និងមាន**ដាក់លូ**ចំនួន៦កន្លែង ដោយ១កន្លែងៗលូ៧កង់ មានមុខកាត់៦តឹក ហើយនិង**ធ្វើស្ពាន**១កន្លែង មានប្រវែង៥០ម៉ែត្រ ទទឹង៧ម៉ែត្រ ជាប្រភេទស្ពានចាក់បេតុង នៅចំណុចអូរតាឃី។<br>- **ខ្សែទី៣**នៅភូមិកោះផ្ដៅ មានប្រវែង៣២៧០ម៉ែត្រ និងមាន**ដាក់លូ**ចំនួន២កន្លែង ដោយក្នុង១កន្លែងៗលូ៨កង់ មានមុខកាត់៨តឹក ពីព្រំប្រទល់ភូមិសំភិន ទៅព្រំប្រទល់ភូមិកំពង់ក្របី ហើយនិង**ធ្វើស្ពាន**៣កន្លែងជាប្រភេទស្ពានចាក់បេតុង ស្ពានទី១នៅចំណុចព្រំប្រទល់ភូមិសំភិន មានប្រវែង២៥ម៉ែត្រ ទទឹង៧ម៉ែត្រ ស្ពានទី២នៅចំនុចអូរព្រៃកផ្ដៅ មានប្រវែង៤៨ម៉ែត្រ ទទឹង៧ម៉ែត្រ ស្ពានទី៣នៅចំណុចអូរមាន់ដប់ មានប្រវែង៣៥ម៉ែត្រ ទទឹង៧ម៉ែត្រ។<br>- **ខ្សែទី៤**នៅភូមិទន្សោងធ្លាក់ ពីព្រំប្រទល់ភូមិយាវ ទៅព្រំប្រទល់ភូមិអាជេន មានប្រវែង៦០០០ម៉ែត្រ **ដាក់លូ**១១កន្លែង ដោយ១កន្លែងៗប្រើលូ៧កង់ដែលមានមុខកាត់៤តឹក និង**ធ្វើស្ពាន**៤កន្លែងជាប្រភេទស្ពានចាក់បេតុង ស្ពានទី១នៅចំណុចអូរត្រួត មានប្រវែង៦០ម៉ែត្រ ទទឹង៧ម៉ែត្រ ស្ពាន ទី២នៅចំណុចអូរព្រៃ មានប្រវែង៥២ម៉ែត្រ ទទឹង៧ម៉ែត្រ ស្ពានទី៣នៅចំណុចទន្សោងធ្លាក់ មានប្រវែង៣០ម៉ែត្រ ទទឹង៧ម៉ែត្រ និងស្ពានទី៤នៅចំណុចអូរព្រៃកស្វាយ មានប្រវែង២៥ម៉ែត្រ ទទឹង៧ម៉ែត្រ។<br>- **ខ្សែទី៥**នៅភូមិយាវ មានប្រវែង១១,០០០ម៉ែត្រ ពីចំណុចព្រំប្រទល់ភូមិដងទង់ ទៅព្រំប្រទល់ភូមិទន្សោងធ្លាក់ ដែល**ប្រើលូ**៥កន្លែង ដោយក្នុង១កន្លែងៗប្រើលូ៧កង់ មុខកាត់៨តឹក៣កន្លែង និងមុខកាត់៥តឹក២កន្លែង ហើយនិង**ធ្វើស្ពាន**ចំនួន៣កន្លែងគឺ ស្ពានទី១នៅចំណុចព្រៃកជ្រៅ ជាប្រភេទស្ពានឈើ មានប្រវែង១៨ម៉ែត្រ ទទឹង៤ម៉ែត្រ ស្ពានទី២នៅចំនុចអូរយាវ ជាប្រភេទបេតុង មានប្រវែង១១០ម៉ែត្រ ទទឹង៧ម៉ែត្រ ស្ពានទី៣នៅចំណុចអូរគំខ្មែង ជាប្រភេទស្ពានបេតុង មានប្រវែង៧០ម៉ែត្រ ទទឹង៧ម៉ែត្រ។<br>- **ខ្សែទី៦**នៅភូមិអាជេន មានប្រវែង៨០០០ម៉ែត្រ ពីចំណុចព្រំប្រទល់ភូមិទន្សោងធ្លាក់ ទៅដល់ចំណុចខ្សាច់ខ្ពស់។<br>• ភូមិសំភិន សុំ**ស្ពាន**១កន្លែង មានប្រវែង៧០ម៉ែត្រ ទទឹង៤,៥ម៉ែត្រ នៅចំណុចព្រៃកអណ្ដូង ជាប្រភេទស្ពានឈើ។ សំណើទាំងអស់ខាងលើនេះសូមចាប់ផ្ដើមធ្វើឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។ |
| **៣. ការសាងសង់មណ្ឌលសុខភាព** |
| • សុំសាងសង់មណ្ឌលសុខភាពសម្រាប់ឃុំកំពង់ចាម ដោយសាងសង់នៅចំណុចក្បែសាលាឃុំ មានចំនួន៣អាគារធ្វើពីថ្មគឺអាគារពិនិត្យជម្ងឺទូទៅ អាគារឆ្មប អាគារសម្រាកព្យាបាលជម្ងឺទូទៅ ហើយនិងសុំគ្រូពេទ្យចំនួន១០នាក់ ដែលមានជំនាញច្បាស់លាស់ រួមទាំងសំភារៈបរិក្ខារ ថ្នាំពេទ្យគ្រប់គ្រាន់ផង។ |

សូមឲ្យបាននៅឆ្នាំ២០១២នេះ។

**៤. ការធ្វើអណ្តូងស្នប់**

- សុំ**អណ្តូងស្នប់**សម្រាប់ភូមិទាំង៥មានដូចជា៖ ***ភូមិអំពិលទឹក***ចំនួន៣អណ្តូង ដោយដាក់នៅចំណុចសាលាបឋមសិក្សាអំពិលទឹក១អណ្តូង នៅចំណុចផ្ទះតាស៊ន១អណ្តូង និងនៅចំណុចផ្ទះតាធា១អណ្តូង ***ភូមិកំពង់ក្របី***ចំនួន៤អណ្តូង ដាក់នៅចំណុចសាលាបឋមសិក្សាកំពង់ក្របី១អណ្តូង ផ្ទះស្រីសេង ១អណ្តូង ផ្ទះបកសុខ១អណ្តូង និងនៅវត្តកំពង់ក្របី១អណ្តូង ***ភូមិទន្សោងធ្លាក់***ចំនួន៥អណ្តូង ដោយដាក់នៅចំណុចភូមិស្ពានក្តារ៣អណ្តូង ចំណុចភូមិឆ្មាយ២អណ្តូង ***ភូមិកោះផ្តៅ***ចំនួន១អណ្តូង ដាក់នៅចំណុចសាលាបឋមសិក្សាកោះផ្តៅ ***ភូមិយារ***ចំនួន៥អណ្តូង ដោយដាក់នៅចំណុចសាលាបឋមសិក្សាយារ ១អណ្តូង សាលាបឋមសិក្សាអូរត្រួត១អណ្តូង ស្រែព្នី២អណ្តូង និងចំណុចបារាយ១អណ្តូង។ សូមចាប់ផ្តើមឆ្នាំ២០១២ និងបញ្ចប់ឆ្នាំ២០១៣។

**៥. ការសាងសង់សាលារៀន**

- ប្រជាពលរដ្ឋនៅ***ភូមិអាជេន***ស្នើសុំឲ្យសាងសង់សាលាបឋមសិក្សាចំនួន១ខ្នង មាន៥បន្ទប់ ចាក់បេតុងប្រក់ក្បឿង ហើយមានសំភារៈ និងឯកសារបង្រៀនគ្រប់គ្រាន់ និងសុំ**គ្រូបង្រៀន**ចំនួន៥នាក់។ សូមឲ្យបាននៅឆ្នាំ២០១២នេះ។

មុនពេលបញ្ចប់សិក្ខាសាលាមានកម្មវិធីប្រគល់របាយការណ៍ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។

លោក **ឈិត ណាន** តំណាងគណបក្សប្រជាជនកម្ពុជា ជាប្រធានក្រុមប្រឹក្សាឃុំ បានមានប្រសាសន៍ថា «តម្រូវការដែលប្រជាពលរដ្ឋលើកឡើងនេះមានក្នុងផែនការអភិវឌ្ឍន៍ឃុំឆ្នាំ២០១២នេះហើយ តែអ្វីដែលសំខាន់នោះគឺ ប្រជាពលរដ្ឋមិនទាន់បានចូលរួមជាមួយឃុំនៅគ្រប់ដំណាក់កាលធ្វើផែនការនៅឡើយ។ ហើយក្នុងនាមលោកជាតំណាងគណបក្សប្រជាជន លោកនឹងពាំនាំយកនូវតម្រូវការទាំង៥នេះទៅស្រុក-ខេត្ត និងជាតិដើម្បីដាក់បញ្ចូលក្នុងមហាសន្និបាតបក្សនៅខែកុម្ភៈ ឆ្នាំ២០១២ខាងមុខនេះ»។

លោក **អ៊ុង ស៊ីន** តំណាងគណបក្សសមរង្ស៊ី ជាជំទប់ទី២ បានមានប្រសាសន៍ថា «លោកសប្បាយនិងពេញចិត្តណាស់ដោយឃើញប្រជាពលរដ្ឋមានការផុសផុលក្នុងការចូលរួម ហើយលោកធ្វើការប្តេជ្ញាចិត្តថានឹងជម្រុញឲ្យផែនការទាំង៥នេះបានសម្រេចនាឆ្នាំខាងមុខ»។

លោក **ម៉ា កាន** តំណាងគណបក្សនរោត្តមរណឫទ្ធិ ជាជំទប់ទី១ បានមានប្រសាសន៍ថា «លោកសូមគាំទ្រទាំងស្រុង ព្រោះជាតម្រូវការជាក់ស្តែង និងចាំបាច់របស់ប្រជាពលរដ្ឋ ហើយសូមគាំទ្រចំពោះមតិរបស់លោកមេឃុំផងដែរ»។

**សិក្ខាសាលានេះមានគោលបំណងឲ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបាន៖**

១. ការយល់ដឹងអំពីសិទ្ធិតួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោតក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។

២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ-សង្កាត់របស់ខ្លួន។

៣. តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ ដាច់ស្រយាលនឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដានជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរុប (EU), OXFAM NOVIB, NPA និង Forum Syd

[1]**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖**

១-លោក **ម្លូច បឿត** (មន្ត្រីផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៨៧១ ៣២៦**

២-កញ្ញា **ភោគ ស្រីពេជ្រ** (ជំនួយការផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០៨៩ ៨១៨ ១៧៦**

បេសកម្ម ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌**តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

[1] No. 077